ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ២៥៥ សជណ

ថ្ងៃ.........ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី..០៧....ខែ..........ឆ្នាំ២០១៨

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការបង្កលក្ខណៈឲ្យគណបក្សនយោបាយធ្វើសកម្មភាព ដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៦ ឆ្នាំ២០១៨។

**យោង** :
- ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវអភិបាល** នៃគណៈអភិបាលរាជធានី ខេត្ត ជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងដើម្បីធានាការអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៦ ឆ្នាំ២០១៨ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមហាផ្ទៃសូមស្នើឲ្យរដ្ឋបាលរាជធានី ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយនៅក្រសួងមហាផ្ទៃ ក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ ដូចខាងក្រោម៖

- **អំពីការបើកទីស្នាក់ការកណ្ដាល ឬទីស្នាក់ការសាខានានារបស់គណបក្ស៖** ករណីទីស្នាក់ការកណ្ដាល ឬទីស្នាក់ការសាខាទាំងនោះជាកម្មសិទ្ធឯកជន ត្រូវមានការយល់ព្រមជាមុនពីម្ចាស់កម្មសិទ្ធិទាំងនោះ។
- **អំពីការលើកស្លាកសញ្ញាគណបក្ស ៖** ការលើកស្លាកសញ្ញាគណបក្សនៅទីស្នាក់ការរបស់ខ្លួន ឬលំនៅដ្ឋានឯកជន ឬទីតាំងឯកជន ត្រូវមានការយល់ព្រមជាមុនពីម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងទាំងនោះ។
- **អំពីការជួបប្រជុំមន្ត្រីគណបក្ស ៖** ការជួបប្រជុំមន្ត្រីគណបក្ស អាចរៀបចំធ្វើឡើងនៅទីស្នាក់ការកណ្ដាល ឬទីស្នាក់ការសាខាគណបក្សនីមួយៗ ឬលំនៅដ្ឋានឯកជន ឬទីតាំងឯកជន។ ចំពោះការជួបជុំនៅតាមលំនៅដ្ឋានឯកជន ឬទីតាំងឯកជន ត្រូវមានការយល់ព្រមជាមុនពីម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងទាំងនោះ។

ការបើកទីស្នាក់ការកណ្ដាល ឬទីស្នាក់ការសាខានានារបស់គណបក្ស ការលើកស្លាកសញ្ញាគណបក្ស និងការជួបប្រជុំមន្ត្រីគណបក្ស ដូចដែលបានគូសបញ្ជាក់ជូនខាងលើនេះ គណបក្សនយោបាយនីមួយៗគ្រាន់តែជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់តែប៉ុណ្ណោះ ដោយមិនតម្រូវឲ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរឡើយ លើកលែងតែការជួបប្រជុំនយោបាយនៅតាមទីសាធារណៈ និងការលើកស្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា។ ពេលទទួលបានការជូនព័ត៌មានជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយរួចហើយ អាជ្ញាធរឃុំ សង្កាត់ ត្រូវរាយការណ៍ជូនអាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគាំទ្រ និងសហការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។ គណបក្សនយោបាយសាមី ឬម្ចាស់លំនៅដ្ឋាន ឬម្ចាស់ទីតាំងឯកជន ត្រូវផ្ដល់នូវកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយការយោគយល់អំពីវិធានការសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ។

ចំពោះការជួបប្រជុំនយោបាយ ដែលរៀបចំដោយគណបក្សនយោបាយ ហើយដែលមិនមែនជាសកម្មភាពបាតុកម្ម កូដកម្មដែលស្ថិតក្នុងក្របខណ្ឌច្បាប់ដោយឡែក និងការលើកស្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ ទីប្រជុំជន ឬតាមដងផ្លូវនានា សាមីគណបក្សនយោបាយត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ពាក្យសុំជួបប្រជុំនយោបាយ និងលើកស្លាកសញ្ញាគណបក្សនយោបាយដូចករណីខាងលើនេះ ត្រូវដាក់ជូនទៅអាជ្ញាធរឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនការជួបប្រជុំ ឬការលើកស្លាកសញ្ញា។ អាជ្ញាធរឃុំ សង្កាត់ ត្រូវពិចារណាអំពីសំណើនេះ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន អំពីបញ្ហាសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាព ពិសេសសុវត្ថិភាពចរាចរ សោភ័ណភាព និងអនាម័យសាធារណៈ ហើយត្រូវឆ្លើយតបចំពោះសំណើសុំក្នុងរយៈពេល១(មួយ)ថ្ងៃបន្ទាប់ពីទទួលសំណើ។ ក្នុងករណីអាជ្ញាធរឃុំ សង្កាត់មិនអាចសម្រេចបាន អាជ្ញាធរឃុំ សង្កាត់ត្រូវធ្វើការស្នើសុំយោបល់ពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត រួចហើយអាជ្ញាធរឃុំ សង្កាត់ត្រូវឆ្លើយតបទៅសាមីគណបក្សវិញយ៉ាងតិច ១(មួយ)ថ្ងៃ មុនថ្ងៃជួបប្រជុំ ឬលើកស្លាកសញ្ញា។

ការជួបប្រជុំនយោបាយនៅតាមទីសាធារណៈដូចករណីខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវពិគ្រោះពិភាក្សាជាមួយគណបក្សនយោបាយសាមី អំពីវិធានការចាំបាច់ដែលគណបក្សនយោបាយត្រូវផ្ដល់កិច្ចសហការ និងការយោគយល់គ្នាទៅវិញទៅមក អំពីបញ្ហាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងអនាម័យសាធារណៈ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្ត ជ្រាប និងត្រូវចាត់ចែងផ្សព្វផ្សាយដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីផ្តល់កិច្ចសហការគាំទ្រ និងត្រួតពិនិត្យតាមដាន សម្របសម្រួលក្នុងការអនុវត្តកិច្ចការខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**<u>ចម្លងជូន៖</u>**

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព្រះបរមរាជវាំង
- ក្រសួងយុត្តិធម៌
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
  (ដើម្បីជូនជ្រាប)
- ឯកសារ - កាលប្បវត្តិ